៧១៨-លោក យ៉ឺនបារាំង
៧១៩-លោក ម៉ៅរដ្ឋា
៧២០-លោក ម៉ូរដាវី
៧២១-លោក ស្រ៊ូពិសិដ្ឋ
៧២២-លោក មនសុខម៉េង
៧២៣-កញ្ញា ឆាយណាវី
៧២៤-លោក ថូសៀប
៧២៥-កញ្ញា ផនរិទ្ធី
៧២៦-លោក ម៉ាងសុជាតា
៧២៧-លោក រឿងសុវណ្ណថា
៧២៨-លោក សំណាង
៧២៩-លោក ទូតសុខដារ៉ា
៧៣០-កញ្ញា ផលសុធី

៧៣១-លោក ខ្លាងខ្លួន
៧៣២-កញ្ញា យៀនណៃសេង
៧៣៣-លោក លីថាវ៉ាត់
៧៣៤-កញ្ញា វុធយូហ៊ាង
៧៣៥-លោក ស្មានវ៉នី
៧៣៦-លោក ឃាង សុវណ្ណដារ៉ា
៧៣៧-លោក គៀន ណារុំ
៧៣៨-លោក ហុង សុវណ្ណា
៧៣៩-លោក ទន់ សំអន
៧៤០-លោក សុខ ហៀង
៧៤១-លោក រត្ន័ ចាន់ណារ៉េន
៧៤២-លោក ថាច់ គេត
៧៤៣-លោក ផល បូរមី
៧៤៤-កញ្ញា សុង ថាវី
៧៤៥-កញ្ញា នាង ស្រីពៅ
៧៤៦-កញ្ញា មាន ស្រីមុំ
៧៤៨-លោក អាន ម៉ាក់ឌី
៧៤៩-លោក កុយ រដ្ឋា
៧៥០-លោក កែវ សុវណ្ណរ័ត្ន
៧៥១-លោក ខែម គ្រី
៧៥២-លោក ប៉ាង សុខុម
៧៥៣-លោក ទឹង ហាប់
៧៥៤-លោក គេន សុខា
៧៥៥-លោក គៀន ចំរើន
៧៥៦-លោក ធី ផៃចន្ទា
៧៥៧-កញ្ញា មីន សេងហ៊ាង
៧៥៨-កញ្ញា ភាវ ដូងសក្កនា
៧៥៩-លោក ហុង សុភ័ក្រ
៧៦០-លោក តាប់ ជិនស៊ីដែន
៧៦១-លោក សុខ វីន
៧៦២-លោក ជៀក ម៉េងគង់
៧៦៣-លោក សាយ ចន្ទ្រា
៧៦៤-លោក គុជ គីមហេង
៧៦៥-លោក អ៊ុន សាម៉ាន
៧៦៦-លោក សាយ ចិន្តា
៧៦៧-លោក យ៉ិន ចាន់ដារ៉ា
៧៦៨-លោក ឡាត់ ឌីណា
៧៦៩-លោក ស្រី ជ័យរិទ្ធី
៧៧០-លោក ថុង គីមហេង
៧៧១-លោក សាត សុខណាល់

៧៧២-លោក ជុំ ភារម្យ
៧៧៣-លោក ញឹម សាយណ្ណ
៧៧៤-លោក ភី សុខលី
៧៧៥-លោក ឌុច រដ្ឋា
៧៧៦-លោក គឹម ហៀប
៧៧៧-លោក ឆាយ សំណាង
៧៧៨-លោក ប៊ិន ចំរើន
៧៧៩-លោក សេង ប្រុស
៧៨០-លោក ព្រឹម សុជាតិ
៧៨១-លោក យុន សុផាន្នី
៧៨២-លោក អេង ម៉ានិត
៧៨៣-លោក ឃី វិច្ឆិកា
៧៨៤-លោក ម៉ិច សំណាង
៧៨៥-លោក ជ័យ សំនៀង
៧៨៦-លោក ហ៊ន់ កំណត់
៧៨៧-លោក កាក់ សុភមង្គល
៧៨៨-លោក ឈុន វុទ្ធី
៧៨៩-លោក ស្រៀង ចាន់សត្យា
៧៩០-លោក សួរ ម៉ូរ៉ា
៧៩១-កញ្ញា គង់ សោភ័ណ្ឌ
៧៩២-លោក ហៀង គីមហ៊ួង
៧៩៣-លោក ហេង លីដា
៧៩៤-លោក កាក់ មិថុនា
៧៩៥-លោក សុខ លីន
៧៩៦-កញ្ញា ហេង ចាន់រី
៧៩៧-លោក នៅ សកករាជ
៧៩៨-កញ្ញា ខន សៅទី
៧៩៩-លោក លី ចាន់ថា
៨០០-លោក លី រិទ្ធី
៨០១-លោក ហុង ពិទូ
៨០២-លោក ឯន ចំណាន
៨០៣-លោក អៃ សុខឡេង
៨០៤-លោក ខុន សុជា
៨០៥-លោក ខុន សុជាតិ
៨០៦-លោក ប៉ក់ សំអាង
៨០៧-លោក ទូត សុវណ្ណារ៉ា
៨០៨-លោក ឌី សុផាន់ណេត
៨០៩-លោក ហ៊ីប ជឿយ
៨១០-លោក សុខ រដ្ឋា
៨១១-លោក លឹម សុភី

៨១២-លោក ប្រាក់ សុឃីម
៨១៣-លោក ឈៀង សុពិសី
៨១៤-លោក ឡេង ច័ន្ទដារាណារិទ្ធ
៨១៥-លោក សែន ប្រសើរ
៨១៦-លោក គុណ រតនៈ
៨១៧-លោក សាខន វិសុទ្ធ
៨១៨-លោក គូ វាសនា
៨១៩-លោក ចិន ពុទ្ធារ៉ា
៨២០-កញ្ញា សុខ ដាលីន
៨២១-កញ្ញា សោម បូរ៉ានីន
៨២២-លោក ឆេងឈឿន
៨២៣-លោក សយសារីម
៨២៤-លោក ប៉ាន់ចាន់ថន
៨២៥-លោក មិនសេងហ៊ាន់
៨២៦-លោក ស៊ីមសុភ័ណ
៨២៧-លោក សំពុទ្ធា
៨២៨-លោក ហ៊ាងសុខហាវ
៨២៩-លោក ឡាយដារ៉ា
៨៣០-លោក ឡេងសុផាន
៨៣១-លោក អ៊ិនសេរីវុធ
៨៣២-លោក អ៊ឹមឌីណា
៨៣៣-លោក ណុបសុភា
៨៣៤-លោក យឿនចាន់ឡុង
៨៣៥-កញ្ញា ផលមករា
៨៣៦-លោក ជ័យសំអុល
៨៣៧-កញ្ញា ជេតសម្ផស្ស
៨៣៨-លោក ធិនមករា
៨៣៩-លោក ផាតសុផាន់
៨៤០-លោក វ៉ាន់កក្កដា
៨៤១-លោក វ៉ាន់យីវវ៉ាន់ដា
៨៤២-លោក ហ៊ួតសុវណ្ណតារា
៨៤៣-លោក ហ្វូគឹមឈីន
៨៤៤-លោក អេងប៊ុនថន
៨៤៥-លោក ជេតសុជាតិ
៨៤៦-លោក លីមតាំងលី
៨៤៧-កញ្ញា ស៊ឹមភីណា
៨៤៨-លោក បានកន្ទុល
៨៤៩-លោក ងួនវាសនា
៨៥០-លោក ជួនសិតធា
៨៥១-លោក ធូម៉េងថៃ

៨៥២-លោក ចិតជេស្តា
៨៥៣-កញ្ញា ភឹមដានី
៨៥៤-លោក វង្សតារា
៨៥៥-លោក ហ៊ាងសុដារដ្ឋ
៨៥៦-លោក អឹមសុធារក្ស
៨៥៧-លោក អុលរំដួល
៨៥៨-លោក ពិនសុវណ្ណារិទ្ធ
៨៥៩-កញ្ញា ហ៊ីងសិក្ខាដារី
៨៦០-លោក ឈុនចក្រវឌ្ឍ
៨៦១-កញ្ញា ឡាកសូរីយ៉ា
៨៦២-លោក ម៉ែម៉ូលិស
៨៦៣-លោក ចាន់រីន
៨៦៤-លោក តួយទ្រី
៨៦៥-លោក មាចសុភ័ណ្ឌ
៨៦៦-លោក រិទ្ធស៊ីថុល
៨៦៧-លោក លីមវិឆ័យ
៨៦៨-លោក ចាន់សុភ័ក្ត្រ
៨៦៩-លោក ឃិនមិនា
៨៧០-លោក ស៊ូឈាវ
៨៧១-លោក នីម៉ាល័យ
៨៧២-កញ្ញា ហៃម៉ាលី
៨៧៣-លោក ឆេងពន្លក
៨៧៤-លោក ជិនសូស្តី
៨៧៥-លោក ជាសម្បត្តិ
៨៧៦-លោក ថុលមករា
៨៧៧-កញ្ញា វាសនាមករា
៨៧៨-លោក ស៊ឹមពលទិវា
៨៧៩-លោក ស៊ូសុខជាតិ
៨៨០-លោក ផាលីតុលា
៨៨១-លោក សែនសេងហៀន
៨៨២-លោក ប៊ុនគីមស័ន
៨៨៣-លោក អ៊ូច រដ្ឋា
៨៨៤-លោក សាន ពណ្ណារ៉ា
៨៨៥-លោក ស៊ិន ច័ន្ទគ្រឹះស្នា
៨៨៦-លោក នួន ផារ៉ា
៨៨៧-លោក អោម សារាក់ខណ្ឌី
៨៨៨-លោក ហៃម សុខហេង
៨៨៩-លោក មុំ ញ៉ាញ់ប្រាថ្នា
៨៩០-លោក ឈុន សុវណ្ណារិទ្ធ
៨៩១-លោក រុន រតនៈ

៨៩២-លោក យ៉ន សីហា
៨៩៣-លោក ភឹម ចាន់ថា
៨៩៤-លោក ឆុំទិត្យ សម្ផស្ស
៨៩៥-លោក មុត ផារិទ្ធ
៨៩៦-កញ្ញា ឃុត រដ្ឋា
៨៩៧-លោក ជួន ចាន់និត
៨៩៨-លោក យ៉ន ភក្តី
៨៩៩-លោក គង់ ផាន់ណា
៩០០-លោក ពៅ សាកេន
៩០១-លោក ទី សុខ
៩០២-លោក ហាម រតនា
៩០៣-លោក ហួនសីហា
៩០៤-លោក គង់គរី
៩០៥-លោក ប្រាក់ស៊ីវន
៩០៦-លោក ខឹមឧត្តម
៩០៧-លោក អ៊ូងសុផាណេត
៩០៨-លោក គិតចំរើន
៩០៩-លោក ហ៊ួនប៊ុនហេង
៩១០-លោក ទិតភារម្យ
៩១១-លោក ស៊ឹមសុភ័ណ្ឌ
៩១២-លោកឃឹមប៊ុនធឿន
៩១៣-លោក អំម៉ៅ
៩១៤-លោក សេងសក្តិសិលា
៩១៥-លោក ទិតសំណាង
៩១៦-លោក ហោសីហា
៩១៧-លោក កែវបូវណ្ណារិទ្ធ
៩១៨-លោក រស់ជ័យរិទ្ធិ
៩១៩-លោក ហុងរតនា
៩២០-កញ្ញា ម៉ននណារិន
៩២១-លោក ប៉ោភារម្យ
៩២២-លោក សេនវណ្ណដា
៩២៣-លោក លឹម រ៉ាវី
៩២៤-លោក សេងសុភក្តី
៩២៥-លោក ឡៅពិសិដ្ឋ
៩២៦-លោក ហ៊ុនកែវឡាយ
៩២៧-កញ្ញា មៀចស្រីធីម
៩២៨-កញ្ញា ហាង សុវណ្ណណៃ
៩២៩-លោក គឹម សុភី
៩៣០-លោក ដៃភារ៉ា
៩៣១-លោក អ៊ុនផារី

៩៣២-លោក ម៉ៅវុទ្ធី
៩៣៣-លោក ម៉ុលលីដា
៩៣៤-កញ្ញា ហ៊ិតសុធីតា
៩៣៥-លោក លីខេមរា
៩៣៦-កញ្ញា វ៉ិតចាន់ណារី
៩៣៧-លោក អ៊ុយចាន់ថា
៩៣៨-លោក សេងផាផាក់
៩៣៩-លោក ខ្លឹងម៉េងហ៊ឹម
៩៤០-លោក កែវផាន់វុទ្ធី
៩៤១-លោក ហៃលផល្លី
៩៤២-លោក ខៀវសោភ័ត់
៩៤៣-លោក ហ៊ិនតុលា
៩៤៤-លោក ហុងសុវណ្ណដា
៩៤៥-លោក ថៃមចាន់ណា
៩៤៦-កញ្ញា សរ ចាន់ណារី
៩៤៧-កញ្ញា ពិសិដ្ឋកន្និកា
៩៤៨-លោក ថោងខេមរា
៩៤៩-កញ្ញា ត្រីសុខបូ
៩៥០-លោក ដើងសុខវ៉ា
៩៥១-កញ្ញា គាំ ប៉ូលីន
៩៥២-លោក ឌុច សីហា
៩៥៣-លោក ពិសិដ្ឋ រតនា
៩៥៤-លោក ជិន សុធួន
៩៥៥-កញ្ញា ថុង ស៊ីណា
៩៥៦-លោក សន រស្មី
៩៥៧-កញ្ញា អឿន សុវណ្ណារ៉ា
៩៥៨-លោក សាត វណ្ណីន
៩៥៩-កញ្ញា ផាត់ ស្រីនាង
៩៦០-លោក អ៊ុន សុខនៅ
៩៦១-លោក ណូ សំអឿន
៩៦២-លោក ហៀងបញ្ញារិទ្ធ
៩៦៣-កញ្ញា ពៅធីដា
៩៦៤-លោក អឿនមករា
៩៦៥-លោក ផលីសុភ័ក្រ
៩៦៦-លោក ឡូតស៊ីថា
៩៦៧-លោក យន់សុវឌ្ឍនា
៩៦៨-លោក ហ៊ិនតារា
៩៦៩-លោក អេងកុសល
៩៧០-លោក យុន សុជាតិ
៩៧១-លោក បេន ភូមារិទ្ធិ

៩៧២-លោក សុខ យឹម
៩៧៣-កញ្ញា ហៃ សុផាន់ណា
៩៧៤-លោក ត្រី ម៉ាលី
៩៧៥-លោក ពៅ ដា
៩៧៦-លោក ស៊ុន ប៊ុនថេន
៩៧៧-កញ្ញា សយ ស្រីយ៉ា
៩៧៨-លោក ជុំ បញ្ញា
៩៧៩-លោក ហ៊ុន កុសល
៩៨០-លោក វ៉េត ចំរ៉ុង
៩៨១-លោក រុន រិទ្ធី
៩៨២-លោក អុង សំអូន
៩៨៣-លោក ព្រុំ តារារង្សី
៩៨៤-កញ្ញា ម៉ា ធីតា
៩៨៥-លោក លាវ សុខារិទ្ធ
៩៨៦-កញ្ញា ច្រឹង ចាន់ថន
៩៨៧-កញ្ញា អិត កល្យាណ
៩៨៨-លោក សាយ វណ្ណារ៉ា
៩៨៩-លោក ឈឿន សុភេន
៩៩០-លោក ណៃ វណ្ណៈ
៩៩១-លោក ចិន្តា វណ្ណដេត
៩៩២-លោក ឈុំ ភក្តី
៩៩៣-លោក ស្រ៊ិន ផល្លា
៩៩៤-លោក ទីន តាន់តាវី
៩៩៥-លោក ឃិត វ៉ុន
៩៩៦-លោក ជិន វឌ្ឍនៈ
៩៩៧-លោក អោង សុទ្ធារ័ត្ន
៩៩៨-កញ្ញា សួង ស្រីពៅ
៩៩៩-លោក ពុំ ថុល
១០០០-កញ្ញា អៀម ស្រីនុច
១០០១-លោក សឿង វណ្ណធី
១០០២-លោក នៅ ប៊ុនឡុង
១០០៣-លោក គង រដ្ឋា
១០០៤-លោក យ៉ាង ដារ៉ាវង្ស
១០០៥-លោក ឆោម ណាកា
១០០៦-លោក ហួត គីមលាង
១០០៧-លោក រ៉ុង សារេន
១០០៨-លោក សេង ធារិទ្ធ
១០០៩-កញ្ញា អ៊ិត ស្រីវ័ន្ត
១០១០-កញ្ញា កិះ ស្រីកែវ
១០១១-លោក នាក់ សារុណ

១០១២-លោក កាន់ ចាន់លីន

១០១៣-លោក នង សុភា

១០១៤-លោក ពេជ្រ គុណណាំ

១០១៥-លោក គ្រឹង ម៉ើ

១០១៦-លោក ឡុង ផាន់ណា

១០១៧-លោក រី អ៊ីគាង

១០១៨-លោក សុន ធីតា

១០១៩-លោក ប៊ុត ឫទ្ធី

១០២០-លោក ទេព រ៉ានេត

១០២១-លោក សុខ សទ្ធា

១០២២-កញ្ញា បាន សុវណ្ណា

១០២៣-កញ្ញា គោ សេងហុង

១០២៤-លោក ឯម ពិសី

១០២៥-លោក ប្រាជ្ញ រិទ្ធី

១០២៦-កញ្ញា ហាង កន្និថា

១០២៧-កញ្ញា ហុង ដានី

១០២៨-លោក ជា សុផា

១០២៩-លោក ហេង ភារិន

១០៣០-លោក ឌុំ ឡូត

១០៣១-លោក ឈឹម សុទ្រី

១០៣២-លោក សម ពិសី

១០៣៣-លោក យឿន ហុងសេង

១០៣៤-កញ្ញា ហង្ស ណារី

១០៣៥-លោក ចាន់ ផាន់ណូ

១០៣៦-លោក ចេប កុសល

១០៣៧-កញ្ញា សឿង ស្រីមុំ

១០៣៨-លោក ផន សុផារាជ

១០៣៩-លោក នួន រតនៈ

១០៤០-លោក ខាន់ សុផាន្នី

១០៤១-លោក ជន សុផណ្ណា

១០៤២-លោក ស ស៊ីណាត

១០៤៣-លោក អ៊ុំ ប៊ុណ្ណា

១០៤៤-កញ្ញា ស៊ុត ចន្ថា

១០៤៥-កញ្ញា ហង្ស ណារ័ត្ន

១០៤៦-លោក សួស រស្មី

១០៤៧-លោក ឃុត សុខែត្រ

១០៤៨-លោក កែវ ម៉េងហោង

១០៤៩-លោក ហ៊ិន សារ៉ាន

១០៥០-លោក អ៊ុម ប៊ុននី

១០៥១-កញ្ញា ឡុង លីនណា

១០៥២-លោក ស្រេង កុសល
១០៥៣-លោក សឹង ស៊ីថារ៉ូ
១០៥៤-កញ្ញា ទឹម គឹមស្រ៊ី
១០៥៥-កញ្ញា លួន ធីតា
១០៥៦-លោក ស៊ិន ដារ៉ា
១០៥៧-លោក ពៅ ប៉េងលី
១០៥៨-លោក លី ពេជ្រស័ក្ត
១០៥៩-លោក ពៅ លាងគ័ង
១០៦០-លោក អន សារឹម
១០៦១-កញ្ញា លាត សុភី
១០៦២-លោក សំបុល រិទ្ធសក្កិ
១០៦៣-លោក ប៉េង ប៊ុណ្ណារី
១០៦៤-លោក ហង្ស ដារ៉ាវុធ
១០៦៥-លោក មិន សុភឿន
១០៦៦-លោក សាន់ សុភា
១០៦៧-លោក ម៉ៃ លីគា
១០៦៨-លោក អ៊ី វិចិត្ត
១០៦៩-លោក ស្រុង សុខខួច
១០៧០-កញ្ញា អ៊ឹម សោភ័ណម៉ានី
១០៧១-កញ្ញា ណាត សារ៉ាន់
១០៧២-កញ្ញា តិក សេងសុចិត្តា
១០៧៣-លោក គីម សុខគា
១០៧៤-លោក ផូ បូរី
១០៧៥-លោក ប៉ុង ភារម្យ
១០៧៦-លោក ទូច ផាន់ណា
១០៧៧-លោក វឿន សុខវ៉ា
១០៧៨-លោក រស់ ភូមិន្ទសម្មាវាទ
១០៧៩-លោក ឈឹម សុជាតិម៉ារ៉ានី
១០៨០-លោក រី ស៊ីដែន
១០៨១-កញ្ញា នួន ណាវ៉ែន
១០៨២-កញ្ញា នួន ច័ន្ទដា
១០៨៣-លោក ម៉ិល ឧត្តម
១០៨៤-លោក យ៉ុន ចាន់ណា
១០៨៥-លោក ហ៊ឹម សុខាន់ណា
១០៨៦-លោក កាន សុធារិទ្ធ
១០៨៧-លោក ផង់ សូណា
១០៨៨-កញ្ញា ឆេង បុប្ផា
១០៨៩-លោក ភា ធារិទ្ធ
១០៩០-កញ្ញា ឡាំង សុភ័ណ្ឌ
១០៩១-លោក ណាយ រ៉ាន់ណេត

១០៩២-លោក ហ៊ិន គឹមហាន
១០៩៣-លោក ងឿន សោភ័ណ្ឌ
១០៩៤-លោក គឹម កក្កដា
១០៩៥-លោក ណាំង ផានិត
១០៩៦-លោក ហ៊ីម ស៊ីណា
១០៩៧-កញ្ញា ផុន សាវីន
១០៩៨-លោក អ៊ុំ សុភារដ្ឋ
១០៩៩-លោក ម៉ក់ សារួន
១១០០-លោក អួង ម៉េងអ៊ាង
១១០១-លោក យឿង ផេង
១១០២-លោក ខេង ចាន់សារ៉ង
១១០៣-លោក ហ៊ាង សីលា
១១០៤-កញ្ញា នី ចាន់ណា
១១០៥-កញ្ញា សុខ ហុងដេន
១១០៦-កញ្ញា សេន សុខហួយ
១១០៧-កញ្ញា យី ស្រីពេជ
១១០៨-កញ្ញា យី ធារ៉ា
១១០៩-កញ្ញា ឈោង ស្រីឡូត
១១១០-កញ្ញា ម៉េត កែវពិសី
១១១១-កញ្ញា អោក សុខខេង
១១១២-លោក សុខវណ្ណនិត
១១១៣-លោក ប៉ក់ រស់
១១១៤-លោក ថុល សុទ្ធា
១១១៥-លោក ហាក់ ភក្តី
១១១៦-លោក កែវ សុភារី
១១១៧-កញ្ញា លាង សុខខេន
១១១៨-លោក ដាពុធដារ៉ា
១១១៩-កញ្ញា តូច បុប្ផា
១១២០-លោក គឹម តុលា
១១២១-កញ្ញា សោម រដ្ឋា
១១២២-លោក ជៀវ ប៊ុនហេង
១១២៣-លោក នី ប៊ុនធឿន
១១២៤-លោក ស៊ឹម សាវ៉ន
១១២៥-លោក គង់ ឬទ្ធារុធ
១១២៦-លោក សាន ឆៃអ៊ីម
១១២៧-លោក កែវ សុភារុន
១១២៨-លោក រ័ត្ន ផល្លា
១១២៩-លោក កាន់ ចំរុង
១១៣០-លោក ឡាច ឡាយ
១១៣១-លោក ឈិន វិន័យ

១១៣២-លោក អ៊ុន ចាន់នាង
១១៣៣-លោក រឿន រិទ្ធិ
១១៣៤-លោក ថេង ជឿន
១១៣៥-លោក នុន សុខណេង
១១៣៦-លោក វង់ សុស៊ាត
១១៣៧-កញ្ញា សោម ស៊ីណែត
១១៣៨-លោក ស្រ៊ុ សុខុន
១១៣៩-កញ្ញា រឿង សុខខុន
១១៤០-កញ្ញា ហុក លក្ខិណា
១១៤១-កញ្ញា សាំង ឆៃអេង
១១៤២-កញ្ញា ស៊ីម ស៊ីឌឿន
១១៤៣-លោក សេង ម៉េងលាភ
១១៤៤-កញ្ញា ស៊ឹម ស្រីពៅ
១១៤៥-លោក ចាន់ លក្ខណា
១១៤៦-លោក វណ្ណ សីហានាថ
១១៤៧-កញ្ញា ស៊ឹម ស៊ីថេត
១១៤៨-លោក ជួរ រតនា
១១៤៩-លោក អ៊ិល ស៊ីថាវ
១១៥០-លោក សួង ភារុន
១១៥១-លោក សុខ គន្ធារី
១១៥២-កញ្ញា ប៉ែន មុន្នីរ័ត្ន
១១៥៣-លោក រ័ត្ន វឌ្ឍនៈ
១១៥៤-លោក ជុំ វុទ្ធី
១១៥៥-លោក អ៊ុំ សារ៉ា
១១៥៦-កញ្ញា ស៊ីន សុសុន្ទរី
១១៥៧-កញ្ញា ស៊ីន ជាសុន្ទរី
១១៥៨-លោក ណេត ភិរុណ
១១៥៩-លោក ម៉ៅ ស៊ីណា
១១៦០-លោក សុខ សម្បត្តិ
១១៦១-លោក អ៊ុក បូរី
១១៦២-លោក ឆយ ប៊ុនស៊ាង
១១៦៣-លោក ជា សុខអ៊ីម
១១៦៤-លោក មូល សម្បត្តិ
១១៦៥-លោក ស៊ិន ស៊ីវ៉ា
១១៦៦-លោក សឿន រតនៈ
១១៦៧-លោក លី នីន
១១៦៨-លោក ឆន សុផល
១១៦៩-កញ្ញា ឈិន រដ្ឋា
១១៧០-កញ្ញា លួន សុគ្គារី
១១៧១-លោក លួន រដ្ឋា

១១៧២-លោក ទ្រី ស៊ីណាត
១១៧៣-លោក ទូច សុធារ៉ាម
១១៧៤-លោក សៅ ពុធដេណា
១១៧៥-កញ្ញា នី ពុទ្ធីរ៉ា
១១៧៦-លោក ជា កក្កដា
១១៧៧-កញ្ញា ទ្រី វូចនា
១១៧៨-លោក ប៊ូ ចំរើន
១១៧៩-លោក ខាត់ ស៊ីណែត
១១៨០-លោក ឆេង វាសនា
១១៨១-លោក អេង ង៉ូវហេង
១១៨២-លោក សួន រដ្ឋា
១១៨៣-លោក ឃិន សុផារិទ្ធ
១១៨៤-លោក ប៊ិន ស៊ីណា
១១៨៥-លោក ឆែម សុវណ្ណារ៉ា
១១៨៦-កញ្ញា យុង មុយហៀង
១១៨៧-លោក ញឹម សុទ្ធារី
១១៨៨-លោក សែម សុវណ្ណារ៉ា
១១៨៩-កញ្ញា សុខ ស្រីអូន
១១៩០-លោក យន់ រិទ្ធី
១១៩១-លោក គាំ រដ្ឋា
១១៩២-លោក មុត ចាន់ធី
១១៩៣-លោក តេង សុវណ្ណដា
១១៩៤-លោក សឿង ប៊ុនស្រៀង
១១៩៥-កញ្ញា រ៉ាត់ សុធារី
១១៩៦-លោក ហេង ទេពវិសុទ្ធ
១១៩៧-លោក ហេង សុភារម្យ
១១៩៨-កញ្ញា ម៉ុម សុខា
១១៩៩-លោក យូ ប៉ោហេង
១២០០-លោក អ៊ុង ចាន់តារា
១២០១-លោក ថន វណ្ណា
១២០២-លោក ខាត់ សុជា
១២០៣-លោក ប្រាក់ ចន្ថា
១២០៤-លោក រ៉ា បូរី
១២០៥-លោក ប៊ុត ឡុងឌី
១២០៦-លោក រ៉ិត ផានី
១២០៧-កញ្ញា រឿន ចាន់ណា
១២០៨-កញ្ញា ម៉ូវ ស្រីទូច
១២០៩-លោក សួន ធារាជ
១២១០-លោក ឈឿង សុធា
១២១១-លោក លាង ប៊ុនណា

១២១២-លោក ឈួន សុភី

១២១៣-លោក ក្រៃ សុភី

១២១៤-លោក យ៉ែម សារ៉ាត់

១២១៥-លោក អំ សុខុម

១២១៦-កញ្ញា ងួន ធារី

១២១៧-កញ្ញា ពៅ ចាន់នាថ

១២១៨-លោក កង បូរ៉ា

១២១៩-លោក ឈិន សុថាដែត

១២២០-លោក កង សំណាង

១២២១-លោក លីន ជំនោរ

១២២២-លោក សៀក វិសាល

១២២៣-លោក ពុំ ចាន់នឿន

១២២៤-លោក នៅ ឌីណា

១២២៥-លោក កៅ ដាវីត

១២២៦-លោក អាន មីដា

១២២៧-លោក ប៊ុន សារ៉េត

១២២៨-លោក ហុក យ៉េកស្រ៊ន់

១២២៩-លោក ហោ សុខសន្តិភាព

១២៣០-លោក ហួន សុជាតិ

១២៣១-លោក ហួន សុបញ្ញា

១២៣២-លោក គាត សារុន

១២៣៣-លោក ឃ៊ុន សីហា

១២៣៤-លោក គីម រីវ៉ាវ័ន្ត

១២៣៥-លោក មុយ ប៉ោគី

១២៣៦-លោក ណាំ សន្តិភាព

១២៣៧-លោក ជាតូនី

១២៣៨-លោក ទិត្យ សារ៉ាត់ឌី

១២៣៩-កញ្ញា ម៉ៅ ពេញ

១២៤០-កញ្ញា ពេជ្រ ចន្ថា

១២៤១-លោក ស៊ឹង សាលី

១២៤២-លោក សយ ផល្លា

១២៤៣-លោក ពៅ រដ្ឋា

១២៤៤-លោក សុធា សន្និវាស

១២៤៥-លោក ថន សុខុម

១២៤៦-លោក ស៊ូចាន់ឆៃយ៉ា

១២៤៧-លោក ឈុន ឆក

១២៤៨-លោក សុន សិរីវឌ្ឍា

១២៤៩-លោក សុខ ពុទ្ធារិទ្ធ

១២៥០-លោក ជ្រុន ច័ន្ទត្រឹស្នា

១២៥១-លោក ជា ភារម្យ

១២៥២-លោក មុំ ប្រុស
១២៥៣-លោក ហេង ចាន់ឌី
១២៥៤-កញ្ញា ស្រ៊ុន សុលីដា
១២៥៥-កញ្ញា ស្រុន សុលីដា
១២៥៦-កញ្ញា សាត ចន្ទី
១២៥៧-កញ្ញា យុត ភារិន
១២៥៨-លោក យាង ឈាងស៊ី
១២៥៩-លោក ម៉ម សុទន់
១២៦០-លោក គង់ ដារិន
១២៦១-លោក ចក់ ឌីណា
១២៦២-លោក គង់ ដារិន
១២៦៣-លោក ចក់ ឌីណា
១២៦៤-លោក សឹង ដារ៉ា
១២៦៥-លោក ណូយ សែមស័ក្តចន្ទី
១២៦៦-កញ្ញា ជឹម ចាន់សុភ័ត្រា
១២៦៧-កញ្ញា ដួង វណ្ណៈ
១២៦៨-កញ្ញា ជា ផល្លា
១២៦៩-លោក ទិត រង់
១២៧០-លោក សុខ សុវណ្ណមករា
១២៧១-លោក សុខ ចន្ទ័វាសនា
១២៧២-លោក តូច សុភ័ក្រ
១២៧៣-លោក ឃួន បញ្ញា
១២៧៤-លោក យ៉ានវុទ្ធា
១២៧៥-កញ្ញា ប៊ួយ ស៊ីណា
១២៧៦-កញ្ញា គ្រឹត យី
១២៧៧-លោក ជា ស៊ីថាច
១២៧៨-លោក សួង រដ្ឋា
១២៧៩-លោក គាំ កេតសាណា
១២៨០-កញ្ញា ឡេវ សុផល
១២៨១-កញ្ញា ផូ បូផា
១២៨២-លោក ញានបូរី
១២៨៣ -លោក ឃុំយ៉េន
១២៨៤-លោក ហេង ប៊ុនហ៊ួង
១២៨៥-លោក នី ឧត្តម
១២៨៦-លោក ឆុន ចំណាន
១២៨៧-លោក ម៉េន ឧត្តម
១២៨៨-កញ្ញា ស៊ឹម ស៊ីភ័ក្ត
១២៨៩-លោក ទិត បញ្ញា
១២៩០-លោក រៀម ដាណេត
១២៩១-កញ្ញា ឆឹង សុគន្ធា

១២៩២-កញ្ញា លី ចាន់ធឿន
១២៩៣-កញ្ញា ថាន់ ភក្តី
១២៩៤លោក -យៀកស៊ីណា
១២៩៥-លោក ញឹក ឡេវីន
១២៩៦-លោក ឈឹម ចាន់ដេត
១២៩៧-លោក ហួត ណាមូរិទ្ធ
១២៩៨-លោក លី វាសនា
១២៩៩-លោក ឡា ខាន់ណា
១៣០០-លោក ឃុន ខិតខំ
១៣០១-លោក រីន ពុទ្ធា
១៣០២-លោក ទឹត សុខៃ
១៣០៣-លោក កាំង ប៊ុនថន
១៣០៤-កញ្ញា កែ ចាន់
១៣០៥-លោក សឹង ច័ន្ទសុភក្របញ្ញា
១៣០៦-កញ្ញា ប៊ិន សុខលាភ
១៣០៧-លោក ចាន់ វិចិត្រ
១៣០៨-លោក ណាង សាង
១៣០៩-លោក យ៉ែម ជឿន
១៣១០-លោក ទឹម សុខៃ
១៣១១-លោក វ៉ាន សុវណ្ណា
១៣១២-លោក ឈាង ចិត្ត
១៣១៣-លោក ទូច ជា
១៣១៤-លោក សៀ ធីន
១៣១៥-លោក យ៉ែម ជឿន
១៣១៦-លោក ផាន់ ភារម្យ
១៣១៧-លោក វ៉ុយ ណារា
១៣១៨-កញ្ញា ឡេង សុជាតិ
១៣១៩-លោក ឡឹក ភ័ក្រ្ត
១៣២០-កញ្ញា ជា សីលា
១៣២១-កញ្ញា ឆន ខាត់ណេ
១៣២២-កញ្ញា អ៊ុត សុម៉ាលី
១៣២៣-លោក យ៉ែម វិចិត្រ
១៣២៤-លោកស្រឿន គឹមស្រស់
១៣២៥-លោក កង សុកឡាង
១៣២៦-លោក សន សុខុម
១៣២៧-លោក ព្រាប រតនា
១៣២៨-លោក វង្ស តុន
១៣២៩-លោក គួចសាយអូវ
១៣៣០-កញ្ញា ឡុងតុលា
១៣៣១-កញ្ញា ជា សុគុន្ធី

១៣៣២-លោក យុងសុភក្តិ
១៣៣៣-លោក ស ធិរាជ
១៣៣៤-លោក គួច ពន្លឺ
១៣៣៥-លោក ទ្រី សិទ្ធី
១៣៣៦-លោក ភឹម ផាន់នី
១៣៣៧-លោក សយ សុណ្ណយ៉ាង
១៣៣៨-លោក ជាន លីដា
១៣៣៩-លោក បៀន សុភ័ក្រ
១៣៤០-លោក ខាន់ សុខេមរៈ
១៣៤១-លោក ពៅ កុសល
១៣៤២-លោក ឡេង ចំរើន
១៣៤៣-លោក អ៊ួន ចាន់មករា
១៣៤៤-លោក យ៉េន សុភក្តិ
១៣៤៥-លោក អ៊ាម វ៉ាន់នៃល
១៣៤៦-លោក ចក់ សុផា
១៣៤៧-កញ្ញា ម៉ៅ វឌ្ឍនា
១៣៤៨-លោក ស៊ាម សុវណ្ណារិទ្ធ
១៣៤៩-លោក វ៉ា រិទ្ធា
១៣៥០-លោក សុខ បញ្ញា
១៣៥១-លោក រុន ដារ៉ូ
១៣៥២-លោក ស្រ៊ុន សុផាន់ណា
១៣៥៣-លោក ព្រាប នារ៉ា
១៣៥៤-លោក ឆែ សាលីដេត
១៣៥៥-លោក ណុល ណុច
១៣៥៦-លោក អាន សុភី
១៣៥៧-លោក ផូ ពិសិដ្ឋ
១៣៥៨-លោក គន់ សុវិសាល
១៣៥៩-លោក នុត សីហា
១៣៦០-លោក ស្រ៊ី សុជាតិ
១៣៦១-លោក ចន ចាន់រ៉ាវី
១៣៦២-លោក ម៉ម សុវណ្ណវ័ត្ត
១៣៦៣-លោក សោម សារឿន
១៣៦៤-លោក តូច បារិត
១៣៦៥-កញ្ញា ហេង ណៃ
១៣៦៦-លោក ទូច រ៉ា
១៣៦៧-លោក សារី វិចិត្រ
១៣៦៨-លោក ផល ពិសិដ្ឋ
១៣៦៩-លោក ប៊ិន សុខគា
១៣៧០-លោក ផេង សុខា
១៣៧១-លោក វង្ស សុវណ្ណតារ៉ា

១៣៧២-លោក សួស ច័ន្ទបណ្ឌិត
១៣៧៣-លោក ឡុង សារី
១៣៧៤-លោក លីន ហាក់លីវណ្ណ
១៣៧៥-លោក គ្រាក់ សារឿន
១៣៧៦-លោក ឆឹល សារុំ
១៣៧៧-លោក អាន ចិត្រ្តា
១៣៧៨-លោក លីន ហាក់លីណា
១៣៧៩-លោក ម៉ៅ បូរ៉ា
១៣៨០-លោក សេង សាន់ណូល
១៣៨១-លោក សុខ សោផាន
១៣៨២-លោក ជា សុផាត
១៣៨៣-លោក ស៊ុំ រដ្ឋា
១៣៨៤-លោក នៅ ម៉ុនដេ
១៣៨៥-លោក អ៊ុក ស្រ៊ុន
១៣៨៦-លោក ប៊ិន សំបឿន
១៣៨៧-កញ្ញា ឆឹល ចន្ទី
១៣៨៨-លោក ផាន់យ៉ុង
១៣៨៩-កញ្ញា សក់ ណារ៉ាត
១៣៩០-លោក ហេង ដារ៉ា
១៣៩១-លោក ណុំ វិបុល
១៣៩២-លោក អ៊ានវង្ស
១៣៩៣-លោក សេង វាសនា

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៧ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអភិវឌ្ឍន៍រួមគ្នា នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ១៤៨សសរ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ
- បានឃើញសេចក្តីសម្រេចលេខ ៣៩ សសរ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ
- បានឃើញតម្រូវការចាំបាច់ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**ប្រការ១**: បង្កើតក្រុមការងារអភិវឌ្ឍន៍រួមគ្នា នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ៖

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **នាង** | **ផាត** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ប្រធាន |
| ២- | ឯកឧត្តម | **សុខ** | **ខាវ៉ាន់** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | អនុប្រធាន |
| ៣- | ឯកឧត្តម | **ស៊ា** | **ម៉ៅ** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- | ឯកឧត្តម | **កៅ** | **ធារ៉ូ** | អនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៥- | ឯកឧត្តម | **ជៀប** | **សួរ** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៦- | ឯកឧត្តម | **ហាក់** | **សុខហេង** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- | លោក | **ជា** | **សុជាតិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |

| | | | | | |
|---|---|---|---|---|---|
| ៨- | លោក | **ហួយ** | **ឧុត្តា** | ប្រធាននាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៩- | លោកស្រី | **យ៉ែម** | **ភាន់នីភា** | ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១០- | លោក | **កែវ** | **ចិសិដ្ឋ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១- | វរសេនីយ៍ឯក | **ទ៉ាន់** | **លីហៀង** | ជំនួយការឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** | សមាជិក |
| ១២- | លោក | **ឈាន** | **សុខុម** | មន្ត្រីនាយកដ្ឋាននីតិកម្ម ក្រសួងរ៉ែ និងថាមពល | សមាជិក |

**ប្រការ២**: ក្រុមការងារអភិវឌ្ឍន៍រួមគ្នា នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ មានភារកិច្ចដូចតទៅៈ

(ក)-ពិភាក្សា និងសិក្សានូវរាល់គំរូស្តីពីការអភិវឌ្ឍរួមគ្នា របស់បណ្តាប្រទេសមួយចំនួន ដែលបានអនុវត្តប្រកបដោយជោគជ័យ។

(ខ)-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ក្នុងករណីចាំបាច់។

(គ)-ធ្វើសេចក្តីរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន ជូនអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ (Sub-JTC) និងគណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ (JTC) ដើម្បីជាមូលដ្ឋានក្នុងការពិចារណា និងលើកសំណើជូនថ្នាក់ដឹកនាំកំពូលពិនិត្យសម្រេច។

**ប្រការ៣**: គ្រប់សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ឬ អនុប្រធាន។

**ប្រការ៤**: ក្រុមការងារមានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៥**: ក្រុមការងារមានសិទ្ធិប្រើប្រាស់មូលនិធិ ដែលជាចំណូលពីវិស័យប្រេងកាត នៃក្រសួងរ៉ែ និងថាមពល តាមរយៈ JTC និង Sub-JTC សម្រាប់បំពេញការងាររបស់ខ្លួន។

**ប្រការ៦**: សេចក្តីសម្រេចលេខ ១៩ សសរ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ និង ខ្លឹមសារទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧**: ប្រធាន និងសមាជិកក្រុមការងារ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៧...សរ.....

**សារាចរ**
**ស្តីពី**
**ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខ្សែបន្ទាត់ព្រំដែន**

កិច្ចការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម គឺជាសកម្មភាពមនុស្សធម៌ដែលធានាសុវត្ថិភាពជូនប្រជាជន រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងការកាត់បន្ថយភាពក្រីក្រ។ កន្លងមករាជរដ្ឋាភិបាលបានផ្សព្វផ្សាយនូវសារាចរណែនាំនិងគោលការណ៍ណែនាំជាបន្តបន្ទាប់ក្នុងគោលបំណងពន្លឿនវឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិសកម្មភាពមីននិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៩របស់ព្រះរាជាណាចក្រកម្ពុជាឲ្យសម្រេចបានជោគជ័យ។ ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខ្សែបន្ទាត់ព្រំដែនត្រូវបានពិនិត្យឃើញថាជាការផ្តល់ប្រយោជន៍យ៉ាងខ្លាំងដល់ប្រជាជនដែលរស់នៅតំបន់នោះ ហើយក៏ជាកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការអនុវត្តអនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្សនិងការបំផ្លាញគ្រាប់មីនហៅកាត់ថាសន្ធិសញ្ញាអូតាវ៉ាដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋហត្ថលេខីផងដែរ។ ប៉ុន្តែការបោសសម្អាតនៅតំបន់ដែលព្រះរាជាណាចក្រកម្ពុជាមិនទាន់ឯកភាពក្នុងការកំណត់ខ្សែបន្ទាត់និងការបោះបង្គោលខណ្ឌសីមាព្រំដែនច្បាស់លាស់អាចបណ្តាលឲ្យមានផលប៉ះពាល់ច្រើនជាមួយប្រទេសជិតខាង ដែលទាមទារឲ្យមានវិធានការសមស្របមុននឹងអាចប្រព្រឹត្តទៅបាន។ ដើម្បីពង្រឹងបន្ថែមនូវប្រសិទ្ធភាពក្នុងការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខ្សែបន្ទាត់ព្រំដែននិងរក្សាទំនាក់ទំនងល្អជាមួយប្រទេសជិតខាងរាជរដ្ឋាភិបាលសូមដាក់ចេញវិធានការដូចខាងក្រោម៖

១- គណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវផ្តល់ជូនអាជ្ញាធរមីននូវផែនទីថតចម្លងទាំងឡាយណាដែលអាចប្រើប្រាស់ជាផ្លូវការបាន ដោយមានការទទួលស្គាល់ពីប្រទេសជាប់ព្រំដែនជាមួយព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការផ្ទៀងផ្ទាត់តំបន់ដែលមានផលប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

២- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ត្រូវសហការជាមួយគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែនជាប្រចាំ ដើម្បីផ្ទៀងផ្ទាត់ពីតំបន់ដែលមានផលប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខ្សែបន្ទាត់ព្រំដែន។

៣- រាល់ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតំបន់ដែលខ្សែបន្ទាត់ព្រំដែននៅមិនទាន់មានការឯកភាពគ្នាពីភាគីទាំងសងខាង ត្រូវសុំការអនុញ្ញាតជាមុនពីគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន តាមរយៈអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន។

៤- រដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចទប់ស្កាត់រាល់ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមក្នុងតំបន់ដែលភាគីទាំងពីរនៅមិនទាន់ឯកភាពគ្នាក្នុងការកំណត់ខ្សែបន្ទាត់ព្រំដែនច្បាស់លាស់និងគ្មានការអនុញ្ញាតពីស្ថាប័នពាក់ព័ន្ធ ហើយត្រូវជូនដំណឹងមកអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីននិងគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីស្វែងរកវិធានការសមស្រប។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន គណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន អាជ្ញាធរថ្នាក់ក្រោមជាតិ ប្រតិបត្តិករបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ក្រុមហ៊ុនធ្វើអាជីវកម្មបោសសម្អាតមីននិងអង្គការពាក់ព័ន្ធត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ៣ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០៩៩...សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វាន់លើកទឹកចិត្តសម្រាប់ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ. ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ(អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន)

## សម្រេច

**ប្រការ១៖**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦៥ " ឧបត្ថម្ភកធន " នៅក្រសួងមហាផ្ទៃ(អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ២៖**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤៖**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

កែ ឃុនដារ៉ា

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ទីកន្លែងទទួល៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ
-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធីឆ្នាំ២០១៦
## របស់ក្រសួងមហាផ្ទៃ ( អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន )

ឯកតាគិត: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៥ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិល រដ្ឋទេយ្យ | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៦ ជុំ | ៦=៣/២ |
| 65 | | | ឧបត្ថម្ភកធន | 10.767.000.000 | 10.767.000.000 | 2.907.090.000 | 7.859.910.000 | 484.515.000 | 27% |
| | 6502 | | ឧបត្ថម្ភកធនដល់អង្គការសាធារណៈ | 10.767.000.000 | 10.767.000.000 | 2.907.090.000 | 7.859.910.000 | 484.515.000 | 27% |
| | | 65024 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម | 10.767.000.000 | 10.767.000.000 | 2.907.090.000 | 7.859.910.000 | 484.515.000 | 27% |
| | | | សរុបរួម = | 10.767.000.000 | 10.767.000.000 | 2.907.090.000 | 7.859.910.000 | 484.515.000 | 27% |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
[illegible]

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៦
ជ. អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
ចាន់ ផល

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦
ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
ជួន ចាន់ឡេង

ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១៦
រដ្ឋទេយ្យករបុរេប្រទាន
ឧត្តមសេនីយ៍ត្រី សឹម ឆាង

បានឃើញនិងឯកភាព
ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
[illegible]

បានឃើញនិងឯកភាព
ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦
ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
កែ គុនជាវ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៧៨៤ ...ឧស.ភ.ន.ព្រក.១១

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ខេមបូ យូនីក ហ្គាម៉ិន ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូ យូនីក ហ្គាម៉ិន (CAMBO UNIQUE GARMENT Ltd.) តំណាងដោយលោកស្រី **CHUNG YIN YUK RITA** បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៦អា សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ ខេមបូ យូនីក ហ្គាម៉ិន"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ០៣៥៨ ឧស.កឧ.ប្រក.១២ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ខេមបូ យូនីក ហ្គាម៉ិន ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : [illegible] ប្រក-១១

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ហុងកុង វីនហ្វែរ ហ្គាមេន (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ហុងកុង វីនហ្វែរ ហ្គាមេន (ខេមបូឌា) អិលធីឌី (HONG KONG WINFAIR GARMENT (CAMBODIA) LTD.) តំណាងដោយ លោកស្រី **YAP SIEW MEE** បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ ភូមិវិជ្ជុល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ ហុងកុង រីនហ៊ែរ ហ្គាមេន (ខេមបូឌា) អិលធីឌី"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ៨២៣ ឧរ៉េ.កឧ.ប្រក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ហុងកុង វីនហ្វៃរ ហ្គាមេន (ខេមបូឌា) អិលធីឌី ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**<u>ចម្លងជូន៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ